## ករណីជោគជ័យ

## នេសាទខុសច្បាប់ ត្រូវបានដោះស្រាយ ក្រោយវេទិកាខុមប្រែល

ក្តីបារម្ភរបស់ប្រជាពលរដ្ឋក្នុងឃុំកំពង់ហារ ចំពោះការនេសាទដោយជនជាតិវៀតណាម ដែលប្រើឧបករណ៍អួនក្រឡាល្អិត និងបញ្ហាការដាក់សម្រះ នៅក្នុងបឹងសាធារណៈជាលក្ខណៈ ឯកជន ត្រូវបានដោះស្រាយក្រោយពេលវេទិកាសាធារណៈខុមប្រែល។ ប្រធានក្រុមប្រឹក្សា ឃុំកំពង់ហារ អាយុ៦២ឆ្នាំ លោកស្រី មាស ចាន់ ថន បានអះអាងថា ក្រោយពេលចូលរួមវេទិកា ខុមប្រែលដើម្បីយល់ដឹងពីបញ្ហារបស់ប្រជាពលរដ្ឋក្នុងឃុំរួចមក ក្រុមប្រឹក្សាឃុំ បានសហការជាមួយអាជ្ញាធរស្រុក អធិការស្រុក និងជលផលខេត្ត ដើម្បីរកយុទ្ធសាស្ត្រដោះស្រាយករណី នេសាទប្រើឧបករណ៍អួនក្រឡាល្អិតពីសំណាក់ ជនជាតិវៀតណាម និងបញ្ហាដាក់សម្រះ នៅក្នុងបឹងសាធារណៈជាលក្ខណៈឯកជន។ លោកស្រីបានមានប្រសាសន៍ថា *"របូត មកដល់ពេល នេះ យើងបាន សហការដោះស្រាយរួចហើយព្រមទាំងប្រជុំប្រាប់ប្រជាពលរដ្ឋ នៅក្នុងឃុំរួចហើយដែរ គឺពុំមានករណីនេះ កើតឡើងទៀតទេ ហើយឆ្នាំក្រោយធ្វើរឹតតែតឹងជាងនេះទៅ ទៀត"។*




ប្រធានក្រុមប្រឹក្សាស្រុក កំពុងធ្វើ ការសន្យាដោះស្រាយបញ្ហានេសាទខុសច្បាប់ និង បញ្ហាដាក់សម្រះជា លក្ខណៈ ឯកជនអំឡុងពេលវេទិកាសាធារណៈខុមប្រែល កាល ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១០ នៅឃុំកំពង់ហារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

បញ្ជាក់ពីស្ថានភាពនៅមូលដ្ឋាន ទំនាក់ទំនងស្រុកខុមប្រែល អាយុ ៣៣ឆ្នាំ អ្នកស្រី យឹម សុផានី បានឲ្យដឹងថា ការនេសាទដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់ មានការអន់ថយច្រើន ក្រោយពេលវេទិកា ដោយលោកស្រីសង្កេតឃើញថា មេភូមិ បានដើរប្រាប់ប្រជាពលរដ្ឋថា គេបានកំណត់ក្រឡាអួនលើសពី៣ធឹង ទើបអនុញ្ញាតអោយនេសាទ ចំណែកបញ្ហាសម្រះវិញ ក៏ពុំឃើញមានទៀតដែរ។

គួរបញ្ជាក់ផងដែរកាលពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១០ អង្គការខុមប្រែលបានរៀបចំវេទិកាសាធារណៈ រវាងក្រុម ប្រឹក្សាស្រុក ខណ្ឌ ឃុំ សង្កាត់ និងប្រជាពលរដ្ឋ នៅឃុំកំពង់ហាវ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដែលមានអ្នក ចូលរួម ប្រមាណ ១៣០នាក់ ក្នុងនោះ ៧៩នាក់ជាស្ត្រី។ កំឡុងពេលធ្វើវេទិកាមានការលើកឡើងនូវបញ្ហាជាច្រើនដូចជា ក្មេងទំនើង ល្បែងស៊ីសង ចោរលួច គោ ក្របី ប៉ុន្តែបញ្ហាការនេសាទនៅតែជាបញ្ហាចំបង និងជាការព្រួយបារម្ភ របស់ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ហាវ ទាំងមូលតែម្តង ព្រោះវាទាក់ទិននឹងការនេសាទប្រើប្រាស់ឧបករណ៍ ខុសច្បាប់ពីសំណាក់ជនជាតិវៀតណាម និងការដាក់សម្រះក្នុងបឹងសាធារណៈរបស់បុគ្គលមួយចំនួន ម្យ៉ាងវិញទៀតបញ្ហានេះ មានការចោទប្រកាន់ថា មានការរួម គំរិតគ្នា រវាងអាជ្ញាធរ និងជនល្មើសថែមទៀតផង។